International Labour Organization

Evaluation Office



i-eval Discovery

# គម្រោងត្រីកោណនៅក្នុងអាស៊ាន៖ ទេសន្តរប្រវេសន៍ការងារដោយសុវត្ថិភាព និងយុត្តិធម៌ – ការវាយតម្លៃចុងក្រោយលើការអនុវត្តគម្រោងដោយទីប្រឹក្សាឯករាជ្យ

## ព័ត៌មានសង្ខេប

ប្រទេស៖ តំបន់អាស៊ាន កម្ពុជា ឡាវ ម៉ាឡេស៊ី មីយ៉ាន់ម៉ា ថៃ និងវៀតណាម

កាលបរិច្ឆេទវាយតម្លៃ៖ ចុចទីនេះ ដើម្បីបញ្ចូលកាលបរិច្ឆេទ

ប្រភេទនៃការវាយតម្លៃ៖ គម្រោង

ពេលវេលានៃការវាយតម្លៃ៖ ចុងក្រោយ

ការិយាល័យរដ្ឋបាល៖ គម្រោងត្រីកោណក្នុងអាស៊ាន៖ ទេសន្តរប្រវេសន៍ការងារដោយសុវត្ថិភាព និងយុត្តិធម៌

ការិយាល័យបច្ចេកទេស៖ MIGRANT

អ្នកគ្រប់គ្រងការវាយតម្លៃ៖ Phumphat Chetiyanonth

ទីប្រឹក្សាវាយតម្លៃ៖ Souphavone Dalavong, Aye Thet Oo, and Ngọc Thanh

និមិត្តសញ្ញា DC៖ RAS/15/05/AUS, RAS/22/54/AUS & RAS/16/01/CAN

ម្ចាស់ជំនួយ និងថវិកា៖ DFAT, AUD 24,000,000 និង GAC, CAD 9,500,000

*ពាក្យគន្លឹះ៖ ទេសន្តរប្រវេសន៍ សមភាពយេនឌ័រ បរិយាបន្នពិការភាព ពលកម្មដោយបង្ខំ*

ការវាយតម្លៃនេះត្រូវបានធ្វើឡើងដោយអនុលោមតាមគោលនយោបាយ និងនីតិវិធីរបស់ ILO។ របាយការណ៍នេះ ពុំត្រូវបានពិនិត្យកែសម្រួលដោយអ្នកជំនាញនោះឡើយ ប៉ុន្តែបានឆ្លងកាត់ការត្រួតពិនិត្យគុណភាពពីការិយាល័យវាយតម្លៃរបស់ ILO។

| សាវតារ និងបរិបទ | |
|---|---|
| សង្ខេបអំពីគោលបំណង ឡូហ្សិក និងរចនាសម្ព័ន្ធនៃគម្រោង | កម្មវិធីត្រីកោណក្នុងអាស៊ាន គឺជាការរួមបញ្ចូលគម្រោងចំនួន ២ ដែលទទួលបានការគាំទ្រពីក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី (DFAT) និងក្រសួងការបរទេសកាណាដា (GAC) ក្នុងគោលបំណងលើកកម្ពស់អភិបាលកិច្ចទេសន្តរប្រវេសន៍ ក្នុងតំបន់អាស៊ាន។ គម្រោងទាំងពីរនេះត្រូវបានបញ្ចូលគ្នានៅក្នុងឆ្នាំ ២០១៨។<br>គោលដៅរួមនៃកម្មវិធីត្រីកោណក្នុងអាស៊ាន គឺដើម្បីបង្កើនការរួមចំណែកនៃទេសន្តរប្រវេសន៍ការងារឱ្យបានជាអតិបរមាដល់កំណើន និងការអភិវឌ្ឍប្រកបដោយស្ថិរភាព និងបរិយាបន្ន ក្នុងតំបន់អាស៊ាន តាមរយៈការបែងចែកផលប្រយោជន៍ឱ្យកាន់តែមានសមធម៌។<br>**លទ្ធផលអន្តរការីទី ១ (ការការពារ)៖** រាល់ពលករទេសន្តរប្រវេសក៍ទាំងអស់បានទទួលការការពារកាន់តែប្រសើរ តាមរយៈក្របខ័ណ្ឌអភិបាលកិច្ចទេសន្តរប្រវេសន៍ការងារ។<br>**លទ្ធផលអន្តរការីទី ២ (ការអភិវឌ្ឍ)៖** គោលនយោបាយ និងកម្មវិធីនានាផ្តល់លទ្ធភាពឱ្យពលករទេសន្តរប្រវេសក៍ទាំងអស់បានរួមចំណែក និងទទួលផលពីការអភិវឌ្ឍសង្គមសេដ្ឋកិច្ច។<br>**លទ្ធផលអន្តរការីទី ៣ (ចល័តភាព)៖** ប្រព័ន្ធចល័តភាពកម្លាំងពលកម្មនាំឱ្យមានបរិវត្តន៍កម្មយេនឌ័រ និងបង្កើនប្រសិទ្ធភាពនៃទីផ្សារការងារ។<br>កម្មវិធីនេះត្រូវបានអនុវត្តនៅថ្នាក់តំបន់ រួមជាមួយនឹងលេខាធិការដ្ឋានអាស៊ាន និងមានសកម្មភាពនៅតាមប្រទេសចំនួនប្រាំមួយ គឺកម្ពុជា ឡាវ ម៉ាឡេស៊ី មីយ៉ាន់ម៉ា ថៃ និងវៀតណាម។ កម្មវិធីនេះត្រូវបានគ្រប់គ្រង ដោយក្រុមការងារកម្មវិធីថ្នាក់តំបន់ ដែលមានបុគ្គលិកកម្មវិធីចំនួន ៤ នាក់ បុគ្គលិកហិរញ្ញវត្ថុ និងរដ្ឋបាលចំនួន ២ នាក់ និងដោយអ្នកសម្របសម្រួលកម្មវិធីថ្នាក់ជាតិ (NPCs) និងមន្ត្រីហិរញ្ញវត្ថុ និងរដ្ឋបាលនៅថ្នាក់ជាតិនៅកម្ពុជា ឡាវ មីយ៉ាន់ម៉ា និងថៃ។ |

| | |
|---|---|
| **ស្ថានភាពបច្ចុប្បន្ននៃគម្រោង** | កម្មវិធីនេះបានទទួលថវិកាគាំទ្រពីក្រសួងការបរទេសកាណាដា រហូតដល់ខែកញ្ញា ឆ្នាំ ២០២៤ និងពីក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី រហូតដល់ខែកញ្ញា ឆ្នាំ ២០២៥ (ដំបូងឡើយ កម្មវិធីនេះទទួលបានថវិកាគាំទ្រ រហូតដល់ខែកញ្ញា ឆ្នាំ ២០២៧ ប៉ុន្តែដោយសារការខ្វះថវិកា ILO និង DFAT បានឯកភាពគ្នាកាត់បន្ថយរយៈពេលអនុវត្តកម្មវិធីនៅដំណាក់កាលនេះ។)<br>នៅក្នុងរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ ២០២៣ មានការរាយការណ៍ថា កម្មវិធីនេះអនុវត្តតាមផែនការ ក្នុងការឈានទៅសម្រេចលទ្ធផលចុងក្រោយរបស់កម្មវិធី រួមទាំងសូចនាករនៅកម្រិតលទ្ធផលរំពឹងទុក និងលទ្ធផលចុងក្រោយភាគច្រើន។ |
| **គោលបំណង វិសាលភាព និងក្រុមគោលដៅនៃការវាយតម្លៃ** | នេះគឺជាការវាយតម្លៃចុងក្រោយ ដោយសារដំណាក់កាលនេះនៃគម្រោងនឹងត្រូវបញ្ចប់ និងមានលទ្ធភាពអាចបន្តនៅដំណាក់កាលមួយទៀត ការវាយតម្លៃនេះផ្តោតលើវឌ្ឍនភាពឈានទៅសម្រេចគោលដៅរបស់កម្មវិធីផង និងកំណត់ពីមេរៀនបទពិសោធ ក្រុមទាំងការវិនិយោគដែលអាចមានក្នុងកម្មវិធីទេសន្តរប្រវេសន៍ការងារក្រោយពេលដែលដំណាក់កាលបច្ចុប្បន្ននៃកម្មវិធីត្រីកោណក្នុងអាស៊ានត្រូវបានបញ្ចប់ផង។<br>ការវាយតម្លៃនេះ គ្របដណ្តប់លើដំណាក់កាលទាំងមូលនៃកម្មវិធី ចាប់តាំងពីការចាប់ផ្តើមនៅក្នុងឆ្នាំ ២០១៥ រហូតដល់ពេលប្រមូលទិន្នន័យនៅខែមីនា ឆ្នាំ ២០២៣ រួមទាំងការអនុវត្តកម្មវិធីនៅក្នុងគ្រប់ប្រទេសអនុវត្តកម្មវិធីទាំងអស់ និងនៅថ្នាក់តំបន់។<br>អតិថិជនសំខាន់ៗនៃការវាយតម្លៃនេះ គឺអ្នកគ្រប់គ្រងកម្មវិធីត្រីកោណនៅអាស៊ាន ការិយាល័យ MIGRANT និងការិយាល័យប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក (ROAP) និងការិយាល័យប្រចាំប្រទេសរបស់ ILO ព្រមទាំង DFAT និង GAC ដែលជាដៃគូអភិវឌ្ឍន៍។ អ្នកប្រើប្រាស់បន្ទាប់ រួមមានលេខាធិការដ្ឋានអាស៊ាន តំណាងនិយោជក កម្មករនិយោជិត និងសង្គមស៊ីវិលនៅថ្នាក់តំបន់ និងសមាជិកត្រីភាគីបូកនៅថ្នាក់ជាតិ។ |

| | |
|---|---|
| **វិធីសាស្ត្រនៃការវាយតម្លៃ** | ការវាយតម្លៃនេះប្រើប្រាស់វិធីសាស្ត្រចម្រុះ ដោយពឹងអាស្រ័យភាគច្រើនលើការប្រមូលទិន្នន័យបែបគុណវិស័យ ដែលត្រូវបានពិនិត្យផ្ទៀងផ្ទាត់ជាមួយនឹងទិន្នន័យបរិមាណវិស័យ ដែលកម្មវិធីបានប្រមូល តាមរយៈដំណើរការពិនិត្យតាមដានរបស់ខ្លួន។ វិធីសាស្ត្រទាំងនេះ រួមមានការពិនិត្យឯកសារ ការសម្ភាសអ្នកផ្តល់ព័ត៌មានសំខាន់ៗ (KIIs) និងការពិភាក្សាក្រុមគោលដៅ (FGDs) និងការប្រមូលករណីសិក្សាដែលបង្ហាញពីការផ្លាស់ប្តូរ។ ការវាយតម្លៃនេះ មានប្រធានក្រុមម្នាក់ និងទីប្រឹក្សាជាតិ ៣ នាក់ សម្រាប់ប្រទេសឡាវ មីយ៉ាន់ម៉ា និងវៀតណាម។ ប្រធានក្រុមវាយតម្លៃបានចុះទៅប្រមូលទិន្នន័យនៅក្នុងប្រទេសកម្ពុជា ឥណ្ឌូនេស៊ី និងថៃ និងបានធ្វើការសម្ភាសពីចម្ងាយជាមួយអ្នកពាក់ព័ន្ធនៅប្រទេសម៉ាឡេស៊ី ដៃគូថ្នាក់តំបន់ និងបុគ្គលដែលគេមិនអាចសម្ភាសដោយផ្ទាល់បានក្នុងអំឡុងពេលចុះប្រមូលទិន្នន័យ។ ទីប្រឹក្សាជាតិបានធ្វើ KIIs និង FGDs ដោយផ្ទាល់ និងពីចម្ងាយនៅតាមប្រទេសរៀងៗខ្លួន។<br>មានអ្នកចូលរួមសរុបចំនួន ៣០៥ នាក់ (ស្រី ១៧៩ នាក់ ប្រុស ១២៦ នាក់) បានចូលរួមក្នុងការវាយតម្លៃនេះ នៅក្នុងការសម្ភាសបុគ្គល និងជាក្រុមចំនួន ១០៣ លើក និងការពិភាក្សាជាមួយនឹងក្រុមគោលដៅចំនួន ២៨ លើក។ នេះរួមមានអ្នកចូលរួមចំនួន ១៨៤ នាក់ (ស្ត្រី ៨៨ នាក់ ប្រុស ៩៦ នាក់) នៅក្នុង KIIs និង ១២១ (ស្រី ៩១ នាក់ ប្រុស ៣០ នាក់) នៅក្នុង FGDs។ ពលករទេសន្តរប្រវេសក៍ចំនួន ១២៦ នាក់ (ស្រី ៩៣ នាក់ ប្រុស ៣៣ នាក់) តំណាងកម្មករនិយោជិត ១៧ នាក់ (ស្រី ៣ នាក់ ប្រុស ១៤ នាក់) តំណាងនិយោជក ៦ នាក់ (ស្រី ១ នាក់ ប្រុស ៥ នាក់) មន្ត្រីរដ្ឋាភិបាល ៥៣ នាក់ (ស្រី ១៩ នាក់ ប្រុស ៣៤ នាក់) មន្ត្រីលេខាធិការដ្ឋានអាស៊ាន ៣ នាក់ (ស្រី ១ នាក់ ប្រុស ២ នាក់) មន្ត្រីអង្គការសង្គមស៊ីវិល និងដៃគូដទៃទៀត ៥៧ នាក់ (ស្រី ៣៤ នាក់ ប្រុស ២៣ នាក់) មន្ត្រីអង្គការសហប្រជាជាតិ ៥ នាក់ (ស្រី ២ នាក់ ប្រុស ៣ នាក់) មន្ត្រីដៃគូអភិវឌ្ឍន៍ ១០ នាក់ (ស្រី ៩ នាក់ |

| | |
|---|---|
| | ប្រុស ១ នាក់) និងមន្ត្រី ILO ២៨ នាក់ (ស្រី ១៧ នាក់ ប្រុស ១១ នាក់) បានចូលរួមនៅក្នុង KIIs និង FGDs។ អ្នកវាយតម្លៃមិនបានសុំឱ្យអ្នកចូលរួមបញ្ជាក់ថាតើពួកគេមានពិការភាពដែរឬអត់នោះឡើយ ក៏ប៉ុន្តែមានជនដែលមានពិការភាពយ៉ាងហោចណាស់ ៦ នាក់ បានចូលរួមសកម្មក្នុងការវាយតម្លៃនេះ ។ |

| | |
|---|---|
| **លទ្ធផលរកឃើញសំខាន់ៗ និងសេចក្តីសន្និដ្ឋាន** | ជារួម កម្មវិធីនេះសម្រេចបានសមិទ្ធផលគួរឱ្យកត់សម្គាល់ ក្នុងការពង្រឹងអភិបាលកិច្ចទេសន្តរប្រវេសន៍នៅក្នុងតំបន់អាស៊ាន និងការផ្តល់សិទ្ធិអំណាចដល់ពលករទេសន្តរប្រវេសក៍ ក្នុងការកំណត់ និងទាមទារសិទ្ធិរបស់ពួកគេ និងទទួលបានការងារសមរម្យ។ ភាពជាដៃគូរឹងមាំ និងការកសាងទំនុកចិត្ត នៅក្នុងរយៈពេលអនុវត្តដ៏វែងរបស់គម្រោង ក៏ជាកត្តាដ៏សំខាន់ដែលជំរុញឱ្យមានការសម្រេចបាននូវសមិទ្ធផលទាំងនេះផងដែរ។ តំបន់អាស៊ានមានតម្រូវការទេសន្តរប្រវេសន៍ការងារដ៏ធំធេង ហើយការបន្តអនុវត្តកម្មវិធីនេះក្រោយដំណាក់កាលបច្ចុប្បន្ននេះ មានសារៈសំខាន់ និងផ្តល់លទ្ធភាពឱ្យកម្មវិធីអាចបន្តសម្រេចបានសមិទ្ធផលនាពេលអនាគត ដើម្បីឆ្លើយតបចំពោះបញ្ហាប្រឈមដែលកំពុងមាននាពេលបច្ចុប្បន្នផង និងដែលកំពុងកើតមានថ្មីៗនៅក្នុងតំបន់នេះផង។<br><br>**ភាពពាក់ព័ន្ធ**<br>ភាពពាក់ព័ន្ធនៃកម្មវិធីនេះចំពោះតម្រូវការរបស់ពលករទេសន្តរប្រវេសក៍ រដ្ឋាភិបាល និយោជក សហជីព និងអង្គការសង្គមស៊ីវិលនៅក្នុងតំបន់អាស៊ានត្រូវបានរកឃើញថាមានកម្រិតខ្ពស់។ កម្មវិធីនេះមានភាពពាក់ព័ន្ធនៅច្រើនកម្រិត ដូចជាការគាំទ្រដល់គណៈកម្មាធិការទទួលបន្ទុកការអនុវត្តសេចក្តីប្រកាសអាស៊ានស្តីពីការការពារ និងការលើកកម្ពស់សិទ្ធិពលករទេសន្តរប្រវេសក៍ (ACMW) ក្នុងការអនុវត្តផែនការការងារប្រចាំឆ្នាំរបស់គណៈកម្មា |

ធិការនេះ ការកសាងសមត្ថភាពបច្ចេកទេសដល់រដ្ឋាភិបាលនៅតាមប្រទេសនីមួយៗ ក្នុងការរៀបចំព្រាង និងអនុវត្តគោលនយោបាយទេសន្តរប្រវេសន៍ឆ្លើយតបចំពោះយេនឌ័រ និងគាំទ្រដល់តួអង្គនៅថ្នាក់ខេត្ត ក្នុងការផ្តល់ព័ត៌មាន និងជំនួយផ្លូវច្បាប់ដល់ពលករទេសន្តរប្រវេសក៏ទាន់ពេលវេលា។ កម្មវិធីនេះត្រូវបានរៀបចំឡើងស្របតាមអនុសញ្ញារបស់ ILO គោលដៅអភិវឌ្ឍន៍ដោយចីរភាព (SDGs) និងកតិកាសញ្ញាសកលស្តីពីទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព សណ្តាប់ធ្នាប់ និងស្របច្បាប់ (GCM)។ ការពុំមានមន្ត្រី NPCs នៅក្នុងប្រទេសម៉ាឡេស៊ី និងវៀតណាម ចាប់តាំងពីឆ្នាំ ២០១៩ មក និងការពុំមានការអអនុវត្តកម្មវិធីនៅថ្នាក់ជាតិនៅក្នុងប្រទេសឥណ្ឌូនេស៊ី និងហ្វីលីពីន មានន័យថា មានចំណុចខ្វះខាតមួយចំនួន ដែលកម្មវិធីពុំបានបំពេញ។

**លទ្ធផលរកឃើញសំខាន់ទី ១៖** ការរៀបចំដែលគិតគូរពីទិដ្ឋភាពចម្រុះ បានជានាឱ្យមានភាពពាក់ព័ន្ធនៅថ្នាក់តំបន់ ថ្នាក់ជាតិ និងថ្នាក់ខេត្ត។

**លទ្ធផលរកឃើញសំខាន់ទី ២៖** កម្មវិធីនេះស្របតាមអាទិភាពរបស់រដ្ឋាភិបាលនៅថ្នាក់ជាតិ និងអ្នកគាំទ្រដល់ការផ្សព្វផ្សាយគោលនយោបាយជាតិទៅដល់ថ្នាក់ខេត្ត។

**លទ្ធផលរកឃើញសំខាន់ទី ៣៖** កម្មវិធីនេះ ឆ្លើយតបចំពោះតម្រូវការនៅថ្នាក់មូលដ្ឋាន ជាពិសេសសិទ្ធិទទួលបានព័ត៌មាន និងសិទ្ធិទទួលបានយុត្តិធម៌។

**លទ្ធផលរកឃើញសំខាន់ទី ៤៖** ការឆ្លើយតបទៅនឹងជំងឺកូវីដ ១៩ មិនត្រឹមតែមានប្រសិទ្ធភាពប៉ុណ្ណោះទេ ថែមទាំងបានជួយបង្កើនការយល់ដឹងដល់អ្នកពាក់ព័ន្ធក្នុងរដ្ឋាភិបាលអំពីតួនាទីសំខាន់ៗដែលអង្គការសង្គមស៊ីវិល និងសហជីពមានក្នុងការជួយដល់ពលករទេសន្តរប្រវេសក៏។

**លទ្ធផលរកឃើញសំខាន់ទី  ៥៖** កម្មវិធីនេះមានចំណុចខ្វះខាតមួយចំនួនដែលបង្កផលប៉ះពាល់តិចតួចលើភាពពាក់ព័ន្ធ ដូចជា វិសាលភាពទីតាំងភូមិសាស្ត្រ ការពុំបានផ្តល់ការបណ្តុះបណ្តាលផ្នែកសន្តិសុខ និងការគាំទ្រផ្នែកសុខ

ភាពផ្លូវចិត្តដល់បុគ្គលិក MRC និងបញ្ហាប្រឈមផ្នែករដ្ឋបាលមួយចំនួនទាក់ទងនឹងសកម្មភាពផ្សព្វផ្សាយ។

**ភាពស៊ីសង្វាក់គ្នា និងសុពលភាពនៃការរចនាគម្រោង**

កម្មវិធីនេះបានប្រើប្រាស់ឧត្តមភាពប្រកួតជែងរបស់ ILO យ៉ាងមានប្រសិទ្ធភាព។ អំណាចកោះប្រជុំ (convening power ) របស់ ILO ត្រូវបានកំណត់ថាបាន រួមចំណែកដល់ការលើកកម្ពស់កិច្ចសន្ទនា និងបង្កើនការចូលរួមរបស់អង្គការវិជ្ជាជីវៈកម្មករនិយោជិត និយោជក និងអង្គការសង្គមស៊ីវិល ក្នុងវេទិកាសំខាន់ៗស្តីពីអភិបាលកិច្ចទេសន្តរប្រវេសន៍នៅថ្នាក់ជាតិ និងថ្នាក់តំបន់ ដោយទទួលបានការគាំទ្រពីអ្នកជំនាញបច្ចេកទេសរបស់ ILO ខាងបទដ្ឋានការងារ និងក្របខ័ណ្ឌបទដ្ឋានរបស់ ILO។ កម្មវិធីនេះ ក៏បានបង្កើតនូវឧត្តមភាពប្រកួតប្រជែងក្នុងអំឡុងរយៈពេលនៃការអនុវត្តផងដែរ ជាពិសេស ការជឿទុកចិត្តដែលកម្មវិធីបានកសាងជាមួយ ACMW ព្រមទាំងអ្នកពាក់ព័ន្ធនៅថ្នាក់តំបន់ និងនៅថ្នាក់ជាតិផ្សេងទៀត ក៏ដូចជាកេរ្តិ៍ឈ្មោះរបស់កម្មវិធី ដែលបានផ្តល់ការគាំទ្រប្រកបដោយគុណភាពដល់មជ្ឈមណ្ឌលធនធានពលករទេសន្តរប្រវេសក៍ (MRCs)។

**លទ្ធផលរកឃើញសំខាន់ទី ៦៖** អំណាចកោះប្រជុំរបស់ ILO ត្រូវបានសមាជិកត្រីភាគី និងអង្គការសង្គមស៊ីវិលចាត់ទុកថាជាចំណុចខ្លាំងដ៏សំខាន់មួយរបស់កម្មវិធីនេះ។

**លទ្ធផលរកឃើញសំខាន់ទី ៧៖** កម្មវិធីត្រីកោណក្នុងអាស៊ានសហការយ៉ាងមានប្រសិទ្ធភាពជាមួយកម្មវិធីផ្សេងទៀតរបស់ ILO។ មិនមែនអ្នកពាក់ព័ន្ធទាំងអស់សុទ្ធតែអាចបែងចែកដាច់រវាងកម្មវិធីត្រីកោណនៅក្នុងអាស៊ាន និងកម្មវិធីរបស់ ILO ដទៃទៀតដែលផ្តោតលើបញ្ហាទេសន្តរប្រវេសន៍នោះឡើយ។

**លទ្ធផលរកឃើញសំខាន់ទី ៨៖** ដៃគូមួយចំនួនបានកសាងកម្លាំងផ្ទួបជាមួយនឹងគម្រោង និងប្រធានបទដទៃទៀតដែលពួកគេកំពុងអនុវត្តការងារជាមួយ។

**លទ្ធផលរកឃើញសំខាន់ទី ៩៖** គេអាចពង្រីកការសហការជាមួយនឹងកម្មវិធីដទៃទៀត ជាពិសេស កម្មវិធីដែលផ្តោតលើការជួញដូរមនុស្ស។

**វឌ្ឍនភាព និងប្រសិទ្ធភាពនៃអន្តរាគមន៍**

កម្មវិធីនេះកំពុងដំណើរការតាមផែនការដែលបានគ្រោងទុក ក្នុងការសម្រេចលទ្ធផលដែលបានគ្រោងទុករបស់ខ្លួន។ កម្មវិធីនេះបានសម្រេចជោគជ័យជាច្រើននៅគ្រប់កម្រិតទាំងអស់របស់កម្មវិធី ដោយសារតែចំណុចខ្លាំងសំខាន់ៗរបស់ខ្លួន។ លទ្ធភាពរបស់កម្មវិធីក្នុងការធានាថាទិន្នន័យដែលបានពីមូលដ្ឋានអាចមានឥទ្ធិពលលើការពិភាក្សាអំពីគោលនយោបាយ និងការសម្រេចចិត្តនៅថ្នាក់តំបន់ និងថ្នាក់ជាតិ និងការធានាថាគោលនយោបាយទាំងនេះពិតជាត្រូវបានអនុវត្តនៅថ្នាក់មូលដ្ឋាន គឺជាកត្តាដែលគាំទ្រដល់ការសម្រេចលទ្ធផលដូចខាងលើ។

**លទ្ធផលរកឃើញសំខាន់ទី ១០៖** កម្មវិធីនេះកំពុងអនុវត្តតាមផែនការដែលបានគ្រោងទុកក្នុងការសម្រេចលទ្ធផលដែលបានគ្រោងទុកស្ទើរតែទាំងអស់នៅដំណាក់កាលបច្ចុប្បន្ននៃកម្មវិធីនេះ។

**លទ្ធផលរកឃើញសំខាន់ទី ១១៖** បើទោះជាមានសុពលភាពក្នុងកម្រិតមួយខ្ពស់ក៏ដោយ គួរមានការពិនិត្យឡើងវិញលើការចាត់ថ្នាក់សូចនាករមួយចំនួន ហើយកត្តាអំណោយផល ដើម្បីលើកស្ទួយភាពអង់អាចដល់ពលករទេសន្តរប្រវេសក៍ ពុំមាននៅក្នុងក្របខ័ណ្ឌលទ្ធផល និងទ្រឹស្តីស្តីពីការផ្លាស់ប្តូរនោះឡើយ។

**លទ្ធផលរកឃើញសំខាន់ទី ១២៖** សមិទ្ធផលសំខាន់ៗ រួមមាន ការចងក្រងបង្កើតក្រុមស្ត្រី ការផ្លាស់ប្តូរគោលនយោបាយជាតិ អនុម័តសេចក្តីប្រកាសគោលការណ៍ណែនាំ និងឧបករណ៍របស់អាស៊ាន ការរៀបចំ និងកែសម្រួលគំរូ MRC ការរួមចំណែកដល់ការពង្រីកមូលដ្ឋានភស្តុតាងអំពីទេសន្តរប្រវេសន៍ និងការកែលម្អកិច្ចសន្ទនាសង្គម និងទំនាក់ទំនងត្រីភាគីបូក ចំណុចខ្លាំងរបស់

កម្មវិធី ដូចជា ការយកចិត្តទុកដាក់ខ្ពស់ចំពោះយេនឌ័រ និងការមិនរើសអើង អំណាចកោះប្រជុំរបស់ ILO ការជំរុញការចូលរួម និងការកសាងសមត្ថភាពរបស់អង្គការសង្គមស៊ីវិល លក្ខណៈចម្រុះរបស់កម្មវិធី រយៈពេល និងភាពបត់បែនរបស់កម្មវិធីជាកត្តាសម្រួលដល់ការសម្រេចបានលទ្ធផលទាំងនេះ ហើយក៏បានរួមចំណែកដល់ការកសាងភាពជាដៃគូរឹងមាំប្រកបដោយការជឿទុកចិត្តគ្នាផងដែរ។

**លទ្ធផលរកឃើញសំខាន់ទី ១៣៖** បញ្ហាប្រឈមសំខាន់ៗដែលកម្មវិធីជួបប្រទះ រួមមាន ថវិកាមានកម្រិត ការយល់ដឹងក្នុងចំណោមអ្នកដែលមានភារកិច្ចត្រូវបំពេញអំពីបញ្ហាប្រឈមដែលជនទេសន្តរប្រវេសន៍ត្រូវជួបប្រទះផ្សេងៗគ្នា ដោយសារការយល់ដឹងរបស់ពួកគេនៅមានកម្រិត ការសម្របសម្រួលរវាងក្រសួងសំខាន់ៗ ការតាមដានលើដំណើរការ AFML នៅក្នុងប្រទេស និងរដ្ឋប្រហារយោធានៅក្នុងប្រទេសមីយ៉ាន់ម៉ា និងបញ្ហាប្រឈមដែលកើតមានជាបន្តបន្ទាប់ពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីនៅប្រទេសនោះ។

**លទ្ធផលរកឃើញសំខាន់ៗ - ប្រសិទ្ធភាពនៃការប្រើប្រាស់ធនធាន**

កម្មវិធីនេះត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាពជាមួយនឹងការប្រើប្រាស់ថវិកាតិចតួច តែសម្រេចបានលទ្ធផលជាដុំកំភួន បើទោះជាដៃគូមួយចំនួនបានលើកឡើងថាការរឹតត្បិតនៅក្នុងកិច្ចព្រមព្រៀងអនុវត្ត គឺជាឧបសគ្គដែលបង្កផលប៉ះពាល់ដល់គុណភាពនៃការអនុវត្តកម្មវិធីក្នុងកម្រិតមួយក៏ដោយ។ ការបញ្ចូលគម្រោងដែលគាំទ្រដោយអូស្ត្រាលី និងកាណាដា ជាកម្មវិធីតែមួយគឺជាជោគជ័យ ដោយបានពង្រឹងភាពបត់បែន និងភាពស៊ីសង្វាក់គ្នានៃវិធីសាស្រ្ត និងជួយដល់ការសន្សំសំចៃការចំណាយ។

**លទ្ធផលរកឃើញសំខាន់ទី ១៤៖** កម្មវិធីត្រីកោណក្នុងអាស៊ាន បានប្រើប្រាស់ថវិកាដ៏តឹងរ៉ឹងប្រកបដោយប្រសិទ្ធភាព ដោយអនុវត្តតាមគោលការណ៍តម្លៃនៃ

លុយ (value for money)។ ការបែងចែកធនធានហាក់បីដូចជាមានភាពសមហេតុសមផល។

**លទ្ធផលរកឃើញសំខាន់ទី ១៥៖** ការបញ្ចូលគម្រោងទាំងពីរនេះបញ្ចូលគ្នាបានពង្រឹងកម្មវិធី ដោយអនុញ្ញាតឱ្យមានភាពបត់បែនកាន់តែច្រើនក្នុងការឆ្លើយតបទៅនឹងតម្រូវការកម្មវិធី ធនធានកាន់តែច្រើនសម្រាប់ការអនុវត្តសកម្មភាពគម្រោង និងសន្សំសំចៃលើចំណាយរដ្ឋបាល។ ការតម្រឹមរយៈពេលផ្តល់មូលនិធិពីប្រភពទាំងពីរ នឹងបង្កើនប្រសិទ្ធភាព តាមរយៈការផ្តល់ភាពច្បាស់លាស់កាន់តែច្រើនដល់ ILO និងដៃគូកម្មវិធី។ កង្វះថវិកាដែលនាំឱ្យមានការដកចេញមន្ត្រី NPCs និងជំនួយការរដ្ឋបាល និងហិរញ្ញវត្ថុនៅក្នុងប្រទេសម៉ាឡេស៊ី និងវៀតណាម ធ្វើឱ្យប្រសិទ្ធភាពការងារមានការថយចុះ។

លទ្ធផលរកឃើញសំខាន់ទី ១៦៖ ការអនុញ្ញាតឱ្យមានភាពបត់បែនកាន់តែច្រើនក្នុងថវិកាសម្រាប់ដៃគូអនុវត្ត និងការបង្កើនចំនួនថវិកាតាមខ្ទង់ អាចជួយបង្កើនគុណភាពនៃសមិទ្ធកម្ម និងប្រសិទ្ធភាពការងារ។

**លទ្ធផលរកឃើញសំខាន់ៗ - ស័ក្តិសិទ្ធិភាពនៃការរៀបចំការគ្រប់គ្រង**

ILO បានបង្កើតប្រព័ន្ធគ្រប់គ្រងដ៏មានប្រសិទ្ធភាព ដោយមានការគាំទ្រពីឯកសារផែនការដែលមានភាពច្បាស់លាស់ និងប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃដ៏រឹងមាំ។ អ្នកពាក់ព័ន្ធភាគច្រើនបានសរសើរដល់ក្រុមការងារកម្មវិធីចំពោះការគាំទ្រប្រកបដោយគុណភាព និងទាន់ពេលវេលា ដែលក្រុមការងារនេះបានផ្តល់ឱ្យ ហើយថ្វីដ្បិតតែកម្មវិធីនេះមានបុគ្គលិកច្រើនក៏ពិតមែន ការមានបុគ្គលិកច្រើនបែបនេះ អាចដោយសារកម្រិតនៃការគាំទ្របច្ចេកទេសដែលគម្រោងបានផ្តល់ដល់ការធ្វើគោលនយោបាយ និងដោយហេតុថាក្រុមការងារកម្មវិធី បានបង្កើតឧបករណ៍ចំណេះដឹងជាច្រើនដោយខ្លួនឯង ជាជាងពឹងផ្អែកលើទីប្រឹក្សាពីខាងក្រៅ។

**លទ្ធផលរកឃើញសំខាន់ទី ១៧៖** កម្មវិធីនេះត្រូវបានគ្រប់គ្រងយ៉ាងមានប្រសិទ្ធភាព ដោយមានការកំណត់តួនាទី និងការទទួលខុសត្រូវច្បាស់លាស់ និងមានការពេញចិត្តខ្ពស់ពីសំណាក់ដៃគូលើកម្រិតដែលមន្ត្រី NPCs និងក្រុមការងារថ្នាក់តំបន់ផ្ដល់ដល់ពួកគេ។

**លទ្ធផលរកឃើញសំខាន់ទី ១៨៖** ប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃ មានលក្ខណៈគ្រប់ជ្រុងជ្រោយ និងគាំទ្រដល់ការគ្រប់គ្រងដែលអាចបត់បែនទៅតាមស្ថានភាពជាក់ស្តែងនៅក្នុងការអនុវត្តកម្មវិធីនេះ។ ប្រព័ន្ធនេះអាចគ្រប់គ្រងការប្រមូលទិន្នន័យពីប្រភពចម្រុះ។ ចាំបាច់ត្រូវបន្តពង្រឹងសមត្ថភាពដៃគូ MRC ក្នុងការប្រមូលទិន្នន័យ ជាពិសេស ផ្ដោតលើការផ្លាស់ប្តូរដែលកម្មវិធីបានរួមចំណែក។

**លទ្ធផលរកឃើញសំខាន់ៗ ការផ្ដោតលើផលជះ និងចីរភាព**

កម្មវិធីត្រីកោណក្នុងអាស៊ានបានរួមចំណែកដល់ការសម្រេចផលជះសំខាន់ៗជាច្រើន ដូចជានៅកម្រិតនៃការធ្វើគោលនយោបាយនៅថ្នាក់ជាតិ និងថ្នាក់តំបន់ និងរួមចំណែកដោយផ្ទាល់ដល់ពលករទេសន្តរប្រវេសក៍នៅតាមមូលដ្ឋាន។ ទោះជាយ៉ាងនេះក្ដី បញ្ហាប្រឈមនៅតែមាននៅក្នុងតំបន់ ហើយគេរំពឹងថាកម្រិតនៃការធ្វើទេសន្តរប្រវេសន៍នឹងបន្តមានការកើនឡើង។ ដូច្នេះ ILO ចាំបាច់ត្រូវបន្តអនុវត្តកម្មវិធី ដែលជួយដល់លេខាធិការដ្ឋានអាស៊ាន រដ្ឋាភិបាលនៅថ្នាក់ជាតិ និងសមាជិកត្រីភាគីបូកផ្សេងទៀត។

**លទ្ធផលរកឃើញសំខាន់ទី ១៩៖** ការផ្លាស់ប្ដូរគោលនយោបាយជាតិ និងគោលនយោបាយនៅថ្នាក់តំបន់បានទទួលការគាំទ្រពីកម្មវិធីត្រីកោណក្នុងអាស៊ាន និងរួមចំណែកនាំឱ្យមានការផ្លាស់ប្តូរដែលនៅគង់វង្សបានយូរអង្វែង។

**លទ្ធផលរកឃើញសំខាន់ទី ២០៖** MRCs បានរួមចំណែកដល់ការលើកកម្ពស់សិទ្ធិអំណាចរបស់ពលករទេសន្តរប្រវេសក៍ជាច្រើននាក់ ជាពិសេសក្រុមស្ត្រី។ គេអាចពិចារណាបញ្ចូលការលើកស្ទួយភាពអង់អាចនេះឱ្យកាន់តែទូលំទូលាយបន្ថែមទៀត ក្នុងរាល់សកម្មភាពទាំងអស់។

ការវាយតម្លៃនេះត្រូវបានធ្វើឡើងដោយអនុលោមតាមគោលនយោបាយ និងនីតិវិធីរបស់ ILO។ របាយការណ៍នេះ ពុំត្រូវបានពិនិត្យកែសម្រួលដោយអ្នកជំនាញនោះឡើយ ប៉ុន្តែបានឆ្លងកាត់ការត្រួតពិនិត្យគុណភាពពីការិយាល័យវាយតម្លៃរបស់ ILO។

**លទ្ធផលរកឃើញសំខាន់ទី ២១៖** អ្នកពាក់ព័ន្ធនៅគ្រប់កម្រិតទាំងអស់របស់កម្មវិធីមានភាពជាម្ចាស់កម្រិតខ្ពស់លើកម្មវិធីនេះ។

**លទ្ធផលរកឃើញសំខាន់ទី ២២៖** ខណៈពេលដែលមានភស្តុតាងមួយចំនួនបង្ហាញថា អ្នកពាក់ព័ន្ធបានធ្វើការប្តេជ្ញាចិត្តថានឹងដាក់ធនធានហិរញ្ញវត្ថុ ឬការប្តេជ្ញាចិត្តផ្សេងទៀត ដើម្បីបន្តការងារដែលបានអនុវត្តកន្លងមក ប្រសិនបើការគាំទ្រពី ILO ត្រូវបានបញ្ចប់។ ការឆ្លើយតបចំពោះចំណុចនេះមានលក្ខណៈចម្រុះ ហើយនឹងមានការកាត់បន្ថយកម្រិតសកម្មភាពខ្លះៗនៅក្នុងផ្នែកជាច្រើន។

**លទ្ធផលរកឃើញសំខាន់ទី ២៣៖** បើទោះជាមានការរីកចម្រើនគួរឱ្យកត់សម្គាល់ក៏ដោយ ចាំបាច់ត្រូវមានកិច្ចខិតខំប្រឹងប្រែងយ៉ាងច្រើន ដើម្បីឆ្លើយតបចំពោះតម្រូវការដែលមានស្រាប់ និងតម្រូវការដែលលេចចេញថ្មីៗជុំវិញអភិបាលកិច្ចទេសន្តរប្រវេសន៍។ ការអនុវត្តកម្មវិធីនាពេលអនាគត គួរជួយឆ្លើយតបចំពោះបញ្ហានេះ។ អាទិភាពដែលត្រូវបានកំណត់ក្នុងអំឡុងពេលវាយតម្លៃ រួមមានការបន្តការងារពាក់ព័ន្ធនឹងចល័តភាព សន្តិសុខសង្គម និងការទទួលស្គាល់ជំនាញ ការបន្តផ្តល់ការគាំទ្រដល់ប្រទេសមីយ៉ាន់ម៉ា និងឡាវ ការបញ្ចូលប្រទេសឥណ្ឌូនេស៊ី និងហ្វីលីពីន ការជ្រើសរើសក្រុមការងារឱ្យបានពេញលេញនៅក្នុងប្រទេសវៀតណាម និងម៉ាឡេស៊ី ការឆ្លើយតបចំពោះបញ្ហាពលកម្មបង្ខំដែលកំពុងលេចឡើង ដូចជានៅតាមមជ្ឈមណ្ឌលឆបោក និងការប្រែប្រួលអាកាសធាតុជាដើម។

**លទ្ធផលរកឃើញសំខាន់ៗ សមភាពយេនឌ័រ និងបរិយាបន្នពិការភាព**

កម្មវិធីត្រីកោណក្នុងអាស៊ាន បានអនុវត្តអភិក្រមភ្លោះ (twin-track) ដើម្បីលើកកម្ពស់សមភាពយេនឌ័រ និងលើកស្ទួយភាពអង់អាចរបស់ស្ត្រី ចាប់តាំងពីពេលដែលកម្មវិធីនេះចាប់ផ្តើម ដូចជាការកំណត់ចំណុចដៅ បម្រុងទុកថវិកាកម្មវិធី ២០% សម្រាប់សកម្មភាពដាក់លាក់ពាក់ព័ន្ធនឹងយេនឌ័រជាដើម។ កម្មវិធីបានសម្រេចលើសពីចំណុចដៅនេះ ដោយថវិកាចំនួន ២៥,៧% ត្រូវ

បានប្រើប្រាស់ សម្រាប់គោលបំណងខាងលើចាប់តាំងពីឆ្នាំ ២០១៥ មក ហើយថ្មីៗនេះថវិកានេះកើនឡើងដល់ជាង ៣០% នៅក្នុងរយៈពេល ២ ឆ្នាំចុងក្រោយ។ ខណៈពេលដែលឥរិយាបថដែលមិនគិតពីយេនឌ័រនៅតែបន្តមានក្នុងចំណោមអ្នកពាក់ព័ន្ធមួយចំនួន កន្លងមកមានការផ្លាស់ប្តូរឥរិយាបថ និងមានការសម្រេចបានលទ្ធផលគួរឱ្យកត់សម្គាល់ ពាក់ព័ន្ធនឹងការរៀបចំគោលនយោបាយដែលយកចិត្តទុកដាក់ចំពោះយេនឌ័រ។ ថ្មីៗនេះ កម្មវិធីនេះបានបង្កើនការយកចិត្តទុកដាក់លើបរិយាបន្នពិការភាព ហើយបើទោះជាវាឆាប់ពេកក្នុងការឃើញលទ្ធផលគួរកត់សម្គាល់ក៏ដោយ វិធីសាស្ត្រដែលបានគ្រោងទុក និងឆន្ទៈរបស់អ្នកពាក់ព័ន្ធសំខាន់ៗមួយចំនួនក្នុងការចូលរួមលើបញ្ហានេះ រួមនឹងការពិគ្រោះយោបល់ជាមួយនឹងអង្គការជនពិការ បង្ហាញឱ្យឃើញពីសក្តានុពលខ្ពស់ក្នុងការអនុវត្តកម្មវិធី ដែលមានលក្ខណៈនវានុវត្តន៍ដែលអាចបង្ហាញពីការអនុវត្តល្អៗដល់កម្មវិធីផ្សេងទៀតរបស់ ILO។

**លទ្ធផលរកឃើញសំខាន់ទី ២៤៖** ការយកចិត្តទុកដាក់ចំពោះពលករទេសន្តរប្រវេសក៍ជាស្ត្រី គឺជាចំណុចខ្លាំងដ៏សំខាន់មួយរបស់កម្មវិធីនេះ។

**លទ្ធផលរកឃើញសំខាន់ទី ២៥៖** មានភ័ស្តុតាងមួយចំនួនដែលបង្ហាញពីការផ្លាស់ប្តូរឥរិយាបថចំពោះអត្តសញ្ញាណយេនឌ័រ និងនិន្នាការភេទ។

**លទ្ធផលរកឃើញសំខាន់ទី ២៦៖** ការងារបរិយាបន្នពិការភាព គឺជារឿងថ្មីរបស់កម្មវិធីនេះ។ ប៉ុន្តែ នៅតាមទីតាំងមួយចំនួនមានភ័ស្តុតាងរួចទៅហើយដែលបង្ហាញពីការយល់ដឹងពីភាពចាំបាច់ក្នុងការពង្រឹងសមត្ថភាព និងរៀបចំកម្មវិធីបរិយាបន្នពិការភាពឱ្យកាន់តែប្រសើរ។ នេះរួមមានការបង្កើតនូវគ្រឹះឱ្យបានរឹងមាំសម្រាប់អភិក្រមនវានុវត្តន៍នាពេលអនាគតចេញពីកម្មវិធីនេះ។

**លទ្ធផលរកឃើញសំខាន់ទី ២៧៖** បន្ថែមលើការធានាថាការអនុវត្តកម្មវិធីនេះមានបរិយាបន្នពិការភាព កម្មវិធីត្រីកោណក្នុងអាស៊ាន មានឱកាសក្លាយជាគំរូផ្ទៃក្នុងរបស់ ILO ដែលបង្ហាញពីរបៀបដែលកម្មវិធីអាចឆ្លើយតបចំពោះសូចនាករនានា នៅក្នុងគោលនយោបាយ និងយុទ្ធសាស្ត្រស្តីពីបរិយាបន្ន

ការវាយតម្លៃនេះត្រូវបានធ្វើឡើងដោយអនុលោមតាមគោលនយោបាយ និងនីតិវិធីរបស់ ILO។ របាយការណ៍នេះ ពុំត្រូវបានពិនិត្យកែសម្រួលដោយអ្នកជំនាញនោះឡើយ ប៉ុន្តែបានឆ្លងកាត់ការត្រួតពិនិត្យគុណភាពពីការិយាល័យវាយតម្លៃរបស់ ILO។

| | |
|---|---|
| | ពិការភាពរបស់ ILO និងយុទ្ធសាស្ត្រស្តីពីបរិយាបន្នពិការភាពរបស់អង្គការសហប្រជាជាតិ ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ។<br>**លទ្ធផលរកឃើញសំខាន់ទី ២៨៖** ការរៀបចំថវិកាឆ្លើយតបចំពោះយេនឌ័រ គឺជាឧបករណ៍ដ៏មានប្រយោជន៍ ដើម្បីឱ្យកម្មវិធីអាចធ្វើការតាមដានការងាររបស់ខ្លួនជុំវិញសមភាពយេនឌ័រ ការបង្ហាញពីភាគរយនៃថវិកាផ្តោតលើសមភាពយេនឌ័រ បញ្ហា SOGIECS និងបរិយាបន្នពិការភាព នឹងជួយពង្រឹងការរៀបចំថវិកាបន្ថែមទៀត។ កម្មវិធីនេះ គួរចែករំលែកបទពិសោធនៃការរៀបចំថវិកាយេនឌ័រដល់ដៃគូអនុវត្តនានារបស់កម្មវិធីត្រីកោណក្នុងអាស៊ាន និងការិយាល័យដទៃទៀតរបស់ ILO។ |

| **អនុសាសន៍ មេរៀនបទពិសោធដែលទទួលបាន និងការអនុវត្តល្អ** | |
|---|---|
| **លទ្ធផលរកឃើញសំខាន់ៗ និងសេចក្តីសន្និដ្ឋាន** | ១. ផ្តល់ថវិកាគាំទ្រសម្រាប់អនុវត្តតាមកម្មវិធីថែមមួយដំណាក់កាលទៀត។<br>២. តម្រឹមរយៈពេលផ្តល់ថវិកាគាំទ្រ ប្រសិនបើអាចធ្វើបាន។<br>៣. ពិនិត្យឡើងវិញលើការចាត់ថ្នាក់សូចនាករក្របខ័ណ្ឌលទ្ធផល និងសម្រួលក្នុងអំឡុងពេលរៀបចំគម្រោងសម្រាប់ដំណាក់កាលណាមួយនាពេលអនាគត។<br>៤. ពិនិត្យឡើងវិញលើទ្រឹស្តីនៃការផ្លាស់ប្តូរ នៅពេលរៀបចំដំណាក់កាលបន្ទាប់នៃការអនុវត្តកម្មវិធី និងបញ្ចូលការពិពណ៌នាអំពីរបៀបដែលលទ្ធផលនានាមានទំនាក់ទំនងជាមួយគ្នា និងបញ្ចូលផ្នែកដែលបច្ចុប្បន្នមិនមាននៅក្នុងកម្មវិធី។<br>៥. គាំទ្រដល់យុទ្ធនាការផ្តោតលើការផ្តល់សច្ចាប័នលើអនុសញ្ញា C189 និង C190។<br>៦. កំណត់ថាតើមានឱកាសផ្តល់ថវិកាគាំទ្រដែលអនុញ្ញាតឱ្យមានការផ្តល់ថវិកាគាំទ្ររួមគ្នាសម្រាប់មុខតំណែង NPC នៅប្រទេសម៉ាឡេស៊ី និងវៀតណាមដែរឬទេ។ |

| | |
|---|---|
| | ៧. ប្រសិនបើអាចរកបានថវិកាគាំទ្រ សូមពង្រីកកម្មវិធី ដើម្បីបញ្ចូលសកម្មភាពថ្នាក់ជាតិនៅក្នុងប្រទេសឥណ្ឌូនេស៊ី និងហ្វីលីពីន។<br>៨. បន្តជានាឱ្យមានការផ្តោតការយកចិត្តទុកដាក់ខ្លាំងលើវិស័យ និងប្រធានបទដែលគាំទ្រដល់គោលនយោបាយដែលនាំឱ្យមានបរិវត្តកម្មយេនឌ័រ។<br>៩. បន្តដាក់ឱ្យដំណើរការការបណ្តុះបណ្តាលអំពីសមភាពពិការភាព និងកសាងសមត្ថភាពដៃគូលើបរិយាបន្នពិការភាព ព្រមទាំងកំណត់រកផ្នែកផ្សេងទៀតនៅក្នុងផ្នែកប្រតិបត្តិការនៃកម្មវិធី ដែលគេអាចលើកកម្ពស់បរិយាបន្នពិការភាពបន្ថែម ដូចជា លទ្ធកម្ម ការជ្រើសរើសបុគ្គលិក និងការរៀបចំឯកសារបោះពុម្ពផ្សាយនានាឱ្យមានភាពងាយស្រួលសម្រាប់ជនមានពិការភាពជាដើម។<br>១០. រៀបចំសាគន្លឹះខ្លីៗ ដើម្បីភ្ជាប់ជាមួយនឹងផលិតផលចំណេះដឹងមួយចំនួន។<br>១១. បញ្ជាក់ជាមួយដៃគូថាពលករទេសន្តរប្រវេសក៍ដែលពុំមានអត្តសញ្ញាណប័ណ្ណនៅតែមានសិទ្ធិចូលរួមក្នុងព្រឹត្តិការណ៍នានា ដែលរៀបចំដោយកម្មវិធី។ ធានាថាក្រុមការងារហិរញ្ញវត្ថុយល់ពីរឿងនេះ។<br>១២. បន្តកំណត់រកវិធី ដើម្បីធ្វើការជាដៃគូជាមួយនឹងកម្មវិធី ASEAN ACT។<br>១៣. បន្តចែករំលែកជោគជ័យនៃកម្មវិធីជាមួយនឹងការិយាល័យប្រចាំតំបន់ និងការិយាល័យប្រចាំប្រទេសផ្សេងទៀត ក៏ដូចជាចែករំលែកជោគជ័យជាសកល តាមរយៈទីស្នាក់ការកណ្តាល និងក្នុងចំណោមដៃគូកម្មវិធី។<br>១៤. ផ្តល់ការបណ្តុះបណ្តាលផ្នែកសន្តិសុខ និងការគាំទ្រ PSS ដល់ភ្នាក់ងារជួរមុខរបស់អង្គការសង្គមស៊ីវិល និងសហជីព។<br>១៥. ប្រសិនបើអាចធ្វើបានផ្តល់ថវិកាគាំទ្រដល់ដៃគូអនុវត្ត ដើម្បីអាចផ្តល់ការបណ្តុះបណ្តាលដល់ដៃគូរបស់ពួកគេ។ |

| | |
|---|---|
| | ១៦. ធ្វើការជាមួយរដ្ឋាភិបាលថ្នាក់ជាតិ ដើម្បីផ្តល់ឱកាសកាន់តែច្រើនដល់ដៃគូមិនមែនរដ្ឋាភិបាល ដើម្បីអាចចូលរួមក្នុងសកម្មភាពពាក់ព័ន្ធនឹង AFML ពេញមួយឆ្នាំ។ |
| មេរៀនសំខាន់ៗ និងការអនុវត្តល្អ | **មេរៀនសំខាន់ៗ**<br>• ខណៈពេលដែលការធានាថាគ្មានការខ្វះខាតនៅក្នុងកិច្ចព្រមព្រៀងអនុវត្ត គឺជាចំណុចវិជ្ជមាន ប្រសិនបើថវិកាតឹងរ៉ឹងពេក វាអាចប៉ះពាល់ដល់គុណភាព និងបណ្តាលឱ្យប្រសិទ្ធភាពមានការថយចុះ។<br>• នៅពេលដែលការរឹតត្បិតថវិកានៅក្នុងកម្មវិធីថ្នាក់តំបន់ ជាការដាក់កំហិតលើការជួលបុគ្គលិកនៅថ្នាក់ជាតិ ការកំណត់រកកម្មវិធី ដើម្បីចែករំលែកចំណាយលើមុខតំណែងបុគ្គលិកជាមួយគ្នា យ៉ាងហោចណាស់អាចកាត់បន្ថយចំណុចខ្វះខាតមួយចំនួនដោយសារតែការខ្វះថវិកាបែបនេះ។<br>**ការអនុវត្តល្អ**<br>• ការបង្កើតក្រុមជនទេសន្តរប្រវេសន៍ជាស្ត្រី គឺជាមុខងារគាំទ្រដ៏សំខាន់សម្រាប់លើកស្ទួយភាពអង់អាចរបស់ស្ត្រី។<br>• ការធានាថាកម្មវិធីដែលថាតំបន់មានទំនាក់ទំនងយ៉ាងរឹងមាំជាមួយនឹងការអនុវត្តនៅថ្នាក់មូលដ្ឋាន ការពង្រឹងភាពជឿជាក់នៃអន្តរាគមន៍ទាំងនេះ ព្រោះថាការមានទំនាក់ទំនងបែបនេះជួយដល់ការប្រមូលទិន្នន័យនៅថ្នាក់មូលដ្ឋាន សម្រាប់ជួយឱ្យមានការអនុវត្តកម្មវិធី និងការស្វែងរកមតិគាំទ្រផ្អែកលើភ័ស្តុតាងនៅថ្នាក់ជាតិ និងថ្នាក់តំបន់។<br>• កម្មវិធីរយៈពេលវែង ដែលមានភាពបត់បែនពីអ្នកផ្តល់ជំនួយ ជួយពង្រឹងការជឿទុកចិត្ត និងកសាងទំនាក់ទំនង និងចុងក្រោយជួយបង្កើនគុណភាពនៃផលិតផលចុងក្រោយ។<br>• ការជួបគ្នារវាងមន្ត្រីមកពីអង្គការសង្គមស៊ីវិល និងមន្ត្រីរដ្ឋាភិបាលជាមួយនឹងតំណាងអង្គការជនពិការ នៅដើមដំណាក់កាលនៃការ |

| | |
|---|---|
| | អនុវត្តកម្មវិធីបរិយាបន្នពិការភាព បង្កើនការយល់ដឹងអំពីបញ្ហាដែលតែងកើតមានឡើង និងដំណោះស្រាយចំពោះបញ្ហាទាំងនេះ និងជួយជានាថាកម្មវិធីអនុវត្តតាមគោលការណ៍ "គ្មានអ្វីអំពីយើង ដោយគ្មានយើងនោះឡើយ"។ |